

# តើខ្ញុំអាចក្លាយជាអ្វី?

Nabila Adani
Nabila Adani



អ្នកគ្រូបានប្រាប់ពួកយើង អោយសរសេរអំពីការងារដែលពួកយើងចង់ធ្វើ នៅពេលដែលពួកយើងធំឡើង។



ហ៊ឹម....តើខ្ញុំគួរធ្វើការងារអ្វី?
នែ! មើលនុ៎ះន៎! ពូម្នាក់នោះកំពុងលក់ការ៉េម។



ខ្ញុំចង់លក់ការ៉េម!

ខ្ញុំអាចដើរជុំវិញភូមិ ហើយញ៉ាំការ៉េមពេញមួយថ្ងៃ។



ប៊ឹងៗ!
ដល់ម៉ោងចេញទៅផ្ទះហើយ។



មើលនុះ! ឡានដឹកសំបុត្រ។



ធ្វើជាអ្នករត់សំបុត្រពិតជាល្អណាស់។ ខ្ញុំអាចធ្វើដំណើរជុំវិញ
ទីក្រុងទាំងមូលបាន។



ម៉ាក់មកយកខ្ញុំទៅផ្ទះវិញហើយ។





ខ្ញុំត្រូវជិះរថភ្លើងដើម្បីទៅផ្ទះលោកយាយខ្ញុំ។



ឈូ! ឈូ!
ខ្ញុំជាអ្នកបើករថភ្លើង។
រថភ្លើងខ្ញុំធ្វើដំណើរទៅកន្លែងឆ្ងាយៗ។
វូហ៊ូ!



ខ្ញុំឆ្ងល់ថាតើយន្តហោះមួយនោះកំពុងហោះទៅណា?



អ្នកបើកយន្តហោះ អាចធ្វើដំណើរទៅគ្រប់ទីកន្លែង។ ឆ្លងសមុទ្រ និងឆ្លងទ្វីប។

ខ្ញុំចូលចិត្តហោះហើរនៅលើអាកាស។



ជ័យោ! ខ្ញុំបានទទួលកញ្ចប់ឥវ៉ាន់មួយពីលោកប៉ារបស់ខ្ញុំ។



ប្រហែលជាខ្ញុំអាចធ្វើជាអ្នកស្រាវជ្រាវសត្វសមុទ្រដូចលោកប៉ាខ្ញុំ។



បន្ទាប់មកខ្ញុំអាចមុជទៅក្នុងទឹកសមុទ្រដ៏ជ្រៅ និងហែលលេង
ជាមួយសត្វសមុទ្រ។



ខ្ញុំឆ្ងល់ណាស់ថា តើមានអ្វីនៅក្នុងប្រអប់នេះ... អស្ចារ្យ!កាំជ្រួច អវកាស!





អុញ! ខ្ញុំបានគេងលក់។



ទីបំផុត ខ្ញុំដឹងថាខ្ញុំចង់ធ្វើអ្វីហើយ ខ្ញុំចង់ក្លាយជាអវកាសយានិកម្នាក់។ ខ្ញុំចង់ស្រាវជ្រាវពីលំហខាងក្រៅហើយនិងទៅទស្សនាភពដទៃនិងផ្កាយជាច្រើនទៀតផងដែរ។

©២០១៩ មូលនិធិអាស៊ី។ គម្រោងតាក់តែងសៀវភៅនេះបានបង្ហាញពីភាពខ្លាំងពូកែរបស់កុមារី និងស្ត្រី តាមរយៈការមានតួអង្គសំខាន់ៗនៅក្នុងរឿងជាស្ត្រី និងកុមារ និងមានការចូលរួមពីអ្នកនិពន្ធ វិចិត្រករ អ្នកកែសម្រួល និងអ្នករចនាជាស្ត្រីទាំងអស់។ សៀវភៅនេះត្រូវបានបង្កើតឡើងតាមរយៈសិក្ខាសាលាស្តីពីការបង្កើតសៀវភៅ ដោយមានការសហការរវាងមូលនិធិLitara និងមូលនិធិអាស៊ី ជាមួយការគាំទ្រពីក្រុមហ៊ុនគ្រឿងសម្អាង Estee Lauder ។ សិក្ខាសាលានិងការអភិវឌ្ឍវិជ្ជាជីវៈ រួមជាមួយនឹងការកែសម្រួល និងរចនាសៀវភៅនេះត្រូវបានធ្វើឡើងដោយមូលនិធិ Litara ។

Brought to you by

The Asia Foundation

Let's Read is an initiative of The Asia Foundation's Books for Asia program that fosters young readers in Asia and the Pacific.
booksforasia.org
To read more books like this and get further information about this book, visit letsreadasia.org

**Original Story**
*Jadi Apa, Ya? (What Could I Become?)*, Author: Nabila Adani. Illustrator: Nabila Adani. Published by The Asia Foundation - Let's Read, © The Asia Foundation - Let's Read. Released under CC BY-NC 4.0.

This work is a modified version of the original story. © The Asia Foundation, 2020. Some rights reserved. Released under CC BY-NC 4.0.

For full terms of use and attribution,
http://creativecommons.org/licenses/by-nc/4.0/
Contributing translators: Somey Chheang and Solyda Say